Learning from home in case of school closures

Information for parents and carers

# ការរៀនសូត្រពីផ្ទះ ក្នុងករណីមានការបិទសាលារៀន

## ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

ប្រសិនបើសាលារៀនរបស់កូនអ្នកចាំបាច់ត្រូវបិទសាលា រៀននឹងទាក់ទងជាមួយគ្រួសារតាមបណ្ដាញធម្មតារបស់ខ្លួន (នេះអាចតាមរយៈអ៊ីម៉ែល សារ SMS វ៉ិបសៃថ៍)។

ប្រសិនបើសាលារៀនត្រូវបិទក្នុងរយៈពេលដ៏យូរ សាលារៀននឹងបន្តផ្ដល់សកម្មភាពរៀនសូត្រសម្រាប់កូនរបស់អ្នកធ្វើនៅផ្ទះ ហើយនឹងទាក់ទងជាមួយអ្នកអំពីការរៀនសូត្ររបស់ពួកគេ។

នៅតាមសាលារៀនជាច្រើនទូទាំងរដ្ឋ គ្រូបង្រៀនបានចាត់ចែងសកម្មភាពរៀនសូត្ររួចរាល់ហើយដោយប្រើឧបករណ៍តាមអនឡាញ។ សាលារៀនខ្លះអាចផ្លាស់ប្ដូរសកម្មភាពរៀនសូត្រច្រើន ឬទាំងអស់របស់កូនអ្នកតាមអនឡាញ។ នេះអាចរួមមានមេរៀនផ្ទាល់មួយចំនួន។ ប្រសិនបើអ្នក ឬសាលា រៀនរបស់អ្នកមិនមានជម្រើសឌីជីថល ឬតាមអនឡាញទេ គេនឹងប្រើយុទ្ធសាស្ត្រមិនមែនឌីជីថល។ នេះអាចរួមមានការផ្ញើសន្លឹកកិច្ចការ សៀវភៅអត្ថបទ ឬ USB ដែលមានសន្លឹកកិច្ចការឌីជីថល និងវីដេអូទៅផ្ទះរបស់អ្នកជាមួយកូនរបស់ អ្នក ឬតាមអ៊ីម៉ែល។

គ្រូបង្រៀនក៏អាចទាក់ទងសិស្សជាក្រុម ឬតាមរយៈការហៅទូរស័ព្ទម្នាក់ទល់នឹងម្នាក់ផ្ទាល់ជាមួយសិស្សដែរ។

សន្លឹកព័ត៌មាននឹងជួយអ្នកឱ្យយល់ពីរបៀបជួយកូនរបស់អ្នករៀនសូត្រនៅផ្ទះ រួមមាន៖

- ការទទួលខុសត្រូវរបស់អ្នក - មានកិច្ចការជាច្រើនដែលអ្នកនឹងត្រូវធ្វើ ដើម្បីជួយកូនរបស់អ្នករៀនសូត្រពីផ្ទះ ដូចជាការរៀបចំទម្លាប់ ការរកកន្លែងស្ងប់ស្ងាត់ និងការសួរនាំពីការរីកចម្រើនលើការរៀនសូត្ររបស់ពួកគេ។
- ការទទួលខុសត្រូវរបស់កូនអ្នក - កូនរបស់អ្នកក៏ចាំបាច់ នឹងត្រូវអនុវត្តតាមទម្លាប់ដែលបានកំណត់សម្រាប់ពួកគេដែរ ហើយបំពេញភារកិច្ចដែលគ្រូបង្រៀនប្រគល់ឲ្យ ខណៈបំពេញកិច្ចការឱ្យអស់ពីសមត្ថភាពរបស់ពួកគេ។
- វិធីរៀបចំផែនការសម្រាប់ថ្ងៃរៀនសូត្ររបស់ពួកគេ - សាលារៀនរបស់អ្នកគួរផ្ដល់ជូនអ្នកនូវដំបូន្មាន និងការណែនាំមួយចំនួនពីអ្វីដែលកូនរបស់អ្នកគួរធ្វើក្នុងអំឡុងពេលថ្ងៃ។
- ការថែរក្សាសុខុមាលភាពរបស់ពួកគេ - អ្នកនឹងចាំបាច់ត្រូវប្រាកដថាពួកគេបានសម្រាក ផឹកទឹក ហើយមិនមានអារម្មណ៍តានតឹង ឬថប់បារម្ភ។
- ការប្រាស្រ័យទាក់ទង - វាជាការសំខាន់ដែលអ្នកត្រូវ និយាយជាមួយកូនរបស់អ្នកជាទៀងទាត់ អំពីការរៀនសូត្ររបស់ពួកគេ។ គ្រូបង្រៀនរបស់កូនអ្នក និង / ឬសាលារៀន នឹងទាក់ទងជាមួយអ្នក ហើយប្រាប់អ្នកពីរបៀបទាក់ទងជាមួយពួកគេ។
- ការប្រើប្រាស់បច្ចេកវិទ្យា និងពេលវេលាលើអេក្រង់ - វាជាការសំខាន់ដែលអ្នកត្រូវត្រួតពិនិត្យកូនរបស់អ្នកឱ្យប្រើបច្ចេកវិទ្យាប្រកបដោយសុវត្ថិភាព និងកំណត់ពេលវេលាដែលពួកគេចំណាយតាមអនឡាញ។

## សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរស័ព្ទទៅនាយកសាលារបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ សេវាកម្មនេះនឹងមិនគិតថ្លៃពីអ្នកទេ។